00686937

E85

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសង

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស : សម្ងាត់ / Confidential / Confidentiel

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: 04/11/2011

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ញត្តិរបស់លោក អៀង សារី សុំយាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ឯកសារបានទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 10 / 05 / 2011
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) និងអនុលោមតាមវិធាន៨៧(៤) និងវិធាន៩៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង យាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម (“សាក្សីដែលត្រូវបានស្នើសុំ”) ដើម្បីថ្វាយ និងផ្តល់សក្ខីកម្មនៅពេលសវនាការបឋម តែទៅលើបញ្ហាអញ្ញត្រកម្មរបស់លោក អៀង សារី ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ដោយផ្អែកលើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស (“RPA”) ប៉ុណ្ណោះ។ ញត្តិនេះត្រូវបានធ្វើឡើងជាចាំបាច់ ដើម្បីឱ្យ អ.វ.ត.ក យល់អំពីសារតារ វិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA ដែលត្រូវបានផ្តល់ឱ្យលោក អៀង សារី កាលពីឆ្នាំ ១៩៩៦។ គេត្រូវតែដឹងអំពីវិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA ដើម្បីកំណត់ថាតើ RPA រារាំងដល់ការផ្តន្ទាទោសលោក អៀង សារី នៅ អ.វ.ត.ក ឬយ៉ាងណា។ សម្តេចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, និងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ រួមជាមួយ លោក អៀង សារី សុទ្ធតែមានការពាក់ព័ន្ធនៅក្នុងការចរចាអំពី RPA។ ពីរភាគបីនៃរដ្ឋសភាជាតិបានឯកភាពតាមសេចក្តីសម្រេចរបស់សម្តេចព្រះវររាជបិតាក្នុងការថ្វាយ RPA។ សម្តេច ជា ស៊ីម កាលនោះគឺជាប្រធានរដ្ឋសភា និងអាចផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងបញ្ហាថាតើរដ្ឋសភាបានឯកភាពលើបញ្ហាអ្វី។ សក្ខីកម្មពីសាក្សីដែលត្រូវបានស្នើសុំមានភាពចាំបាច់ដើម្បីកំណត់អំពីសារតារ វិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA។

## I. **សាវតារ**

១. នៅខែសីហា ឆ្នាំ ១៩៧៩ លោក អៀង សារី ត្រូវបានកាត់ទោស និងផ្តន្ទាទោស *កំបាំងមុខ* ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក៏ដូចជាឧក្រិដ្ឋកម្មផ្សេងៗទៀតជាច្រើន[១]។ សាលក្រមបាន

---

[១] លោក អៀង សារី ត្រូវបានកាត់ទោស និងផ្តន្ទាទោស ដោយកំបាំងមុខ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បន្ថែមលើ:

I. អនុវត្តផែនការសម្លាប់រង្គាលដោយមានខ្សែរយៈ: ប្រព្រឹត្តទៅលើប្រជាជនគ្រប់ប្រភេទគ្រប់ស្រទាប់គ្រប់ ប្រភេទក្នុងសភាពសាហាវឃោរឃៅបំផុត៖ បន ប៉ុល ពត និង អៀង សារី បានសម្លាប់រង្គាល គ្មានរើសមុខថា នេះជានាយទាហាន ឬជាពលទាហាននៃរបបចាស់ សម្លាប់រង្គាលនូវបញ្ញវន្តគ្រប់ជាន់ថ្នាក់ សម្លាប់រង្គាលទាំងមនុស្សទាំងចលនាដែលពួកវាយល់ថាប្រឆាំងនឹងពួកវា។

00686939



ផ្តន្ទាទោសប្រហារជីវិត លោក អៀង សារី និងបានរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់[២]។ លោក អៀង សារី មិនបានស្ថិតនៅក្នុងមន្ទីរឃុំឃាំងនោះទេទាំងមុនពេល ក្នុងអំឡុងពេល និងក្រោយពេលសវនាការ ហេតុដូច្នេះហើយទោសនេះមិនត្រូវបានអនុវត្តនោះទេ។

២. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ លោក អៀង សារី បានចេញសេចក្តីប្រកាសមួយដោយបានថ្កោលទោស ប៉ុល ពត, តាម៉ុក និង សុន សេន និងដោយប្រកាសថា រូបគាត់ និងអ្នកដើរតាមគាត់ នឹង "បង្រួបបង្រួមជាតិទាំងមូលឡើងវិញឆ្ពោះទៅរកការផ្សះផ្សាជាតិពិតប្រាកដ ដែលផ្ទុយទៅនឹងការគិតដែលមិនសមហេតុផលរបស់ ប៉ុល ពត, តាម៉ុក, និង សុន សេន ដែលចូលចិត្តបង្ហូរឈាម ដែលបង្កសង្គ្រាមរហូតដល់ស្លាប់"[៣]។

---

II. ការកាប់សម្លាប់អ្នកដឹកនាំសាសនា សាសនិកជន ការលុបបំបាត់សាសនា ការសម្លាប់រង្គាលជនជាតិ ភាគតិចដោយគ្មានការបែងចែករវាងអ្នកប្រឆាំង និងអ្នកមិនប្រឆាំងនោះទេ សម្រាប់គោលបំណងនៃការ ធ្វើឲ្យជ្រួតជ្រាប។ ការសម្លាប់ជនបរទេស។

III. ការបណ្តេញប្រជាជនចេញពីរដ្ឋធានីភ្នំពេញ ពីទីក្រុង និងជនបទដែលទើបរំដោះនាំឲ្យ មានការវិនាស ហិនហោចដល់មូលដ្ឋានគ្រួសារ មូលដ្ឋានសង្គម និងនាំឲ្យមានការសម្លាប់រង្គាល និងការបង្កើតលក្ខខណ្ឌរស់នៅដែលនាំឲ្យមានការស្លាប់បាត់បង់ជីវិត។

IV. ប្រមូលផ្តុំប្រជាជនឲ្យចូល "សហករណ៍" ដែលជាជំរំប្រមូលផ្តុំក្លែងក្លាយ គាបសង្កត់ ប្រជាជនឲ្យធ្វើការ និងឲ្យរស់នៅក្នុងលក្ខណៈវិនាសអន្តរាយទាំងរូបកាយទាំងស្មារតី សម្លាប់ព្យាបាទយ៉ាងរង្គាល។

V. ឃាតកម្មលើកុមារ និងការបង្វឹកខួរកុមារជំទង់ឲ្យទៅជាជនឃោរឃៅកាចសាហាវក្រៃលែង។

VI. បំផ្លាញសម្ព័ន្ធសេដ្ឋកិច្ច បំផ្លាញខឿនវប្បធម៌ អប់រំ ខឿនសុខាភិបាល

VII. បន្ទាប់ពីការវាយឲ្យរលំដោយកងកម្លាំងប្រដាប់អាវុធស្ម័គ្រចិត្ត បន ប៉ុល ពត - អៀង សារី នៅតែរឹងរូសបន្តការប្រឆាំងនឹងបដិវត្តន៍ដោយប្រព្រឹត្តបទឧក្រិដ្ឋថ្មីៗទៀតក្នុងការកាប់សម្លាប់ អ្នកដែលប្រឆាំងនឹងពួកវា។ ក្នុងរយៈពេល ៤ ឆ្នាំដែលពួកវាប្លន់យកអំណាចដឹកនាំប្រទេស បនប៉ុល ពត-អៀង សារី បានអនុវត្តមាគ៌ា សម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។

*សូមមើល* សាលក្រមរបស់តុលាការប្រជាជនបដិវត្តកម្ពុជា ឯកសារ U.N. A/34/491 ចុះថ្ងៃទី ១៩ សីហា ១៩៧៩ ទំព័រ ៣ដល់២១។

[២] ដូចខាងលើ ទំព័រ ៣៩។

[៣] អៀង សារី, សេចក្តីប្រកាសឆ្នាំ ១៩៩៦ របស់ អៀង សារី, ស្វែងរកការពិត, DC-Cam ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦។

៣. នាដើមខែ កញ្ញា ឆ្នាំ ១៩៩៦ លោក អៀង សារី បានជួបជាមួយសហរដ្ឋមន្ត្រីក្រសួងការពារជាតិរបស់ប្រទេសកម្ពុជាទាំងពីររូប គឺ លោកទៀ បាញ់ និងលោក ទា ចំរ៉ាត់ នៅទីក្រុងបាងកក ដើម្បីស្នើសុំការលើកលែងទោស ដើម្បីជាថ្នូរនឹងការបោះបង់ចោលរដ្ឋាភិបាលកម្ពុជា។ ឧត្តមសេនីយ៍ ទៀ បាញ់ "បានសរសើរ លោក អៀង សារី ចំពោះភាពស្មោះត្រង់ក្នុងការឈានទៅរកការផ្សះផ្សាជាតិ ដោយលើកឡើងថា ការសម្រេចចិត្តរបស់លោកក្នុងការបញ្ចប់ការតស៊ូ ដោយអាវុធរយៈពេលជាច្រើនទសវត្សរ៍ នឹងធ្វើឲ្យមនុស្សរួបរួមគ្នានៅទីបំផុត"[៤]។ លោក អៀង សារី បានថ្លែងថា "ការសម្រេចចិត្តរបស់ខ្លួនមានភាពធំធេងណាស់ ពីព្រោះវាជួយបញ្ចប់សង្គ្រាម សន្សំថវិកា និងចៀសវាងនូវការវិនាសអន្តរាយ"[៥] និងបានគូសបញ្ជាក់ថា វាគ្រាន់តែជាបញ្ហាពេលវេលាប៉ុណ្ណោះ មុនពេលលោក អៀង សារី និងអ្នកដើរតាមគាត់ ត្រូវបានផ្ដល់នូវការលើកលែងទោស[៦]។

៤. បន្ថែមពីលើការចរចាអំពីការផ្ដាច់ខ្លួនរបស់លោក អៀង សារី សហនាយករដ្ឋមន្ត្រី សម្ដេច ហ៊ុន សែន និងសម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានចូលគាល់សម្ដេចព្រះវររាជបិតានរោត្តម សីហនុ ដោយស្នើសុំឲ្យមានការអនុគ្រោះទោស និងការលើកលែងទោស ដល់លោក អៀង សារី។ ព្រះមហាក្សត្របានយល់ព្រមអនុគ្រោះទោស និងលើកលែងទោស ដរាបណាសមាជិកពីរភាគបីនៃរដ្ឋសភាបានគាំទ្រ[៧]។ រដ្ឋសភាបានគាំទ្រ RPA ដែលស្នើដោយសហនាយករដ្ឋមន្ត្រីទាំងពីររូប[៨]។

---

[៤] ការចរចាអំពីការលើកលែងទោសរបស់ អៀង សារី: ការចរចាសម្ងាត់របស់អ្នកកណ្ដាលជាកងទ័ពជាមួយរដ្ឋមន្ត្រី, កាសែតបាងកកប៉ុស្តិ៍ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៦។

[៥] ដូចខាងលើ។

[៦] ដូចខាងលើ។

[៧] ព្រះមហាក្សត្រមានព្រះរាជឱង្ការនាពេលនោះថា៖ "ក្នុងនាមជាព្រះមហាក្សត្រស្របតាមច្បាប់រដ្ឋធម្មនុញ្ញ ដែលគ្រងរាជ្យ ប៉ុន្តែមិនកាន់អំណាច ខ្ញុំព្រះករុណាខ្ញុំនឹងបំពេញជូននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាទាំងពីររូបពាក់ព័ន្ធនឹងបញ្ហានៃការលើកលែងទោសដល់លោក អៀង សារី និងដល់ "អតីត" អ្នកគាំទ្ររបបខ្មែរក្រហមនេះ។ ប៉ុន្តែនៅក្នុង "បញ្ហាលោក អៀង សារី" ដ៏ធ្ងន់ធ្ងរនេះ ខ្ញុំព្រះករុណាខ្ញុំនឹងកំណត់លក្ខខណ្ឌឲ្យមានសមាជិករដ្ឋសភាចំនួន ពីរភាគបី គាំទ្រនាយករដ្ឋមន្ត្រីទាំងពីររូបរបស់យើងមុនពេលព្រះរាជក្រឹត្យលើកលែងទោសត្រូវបានថ្វាយដល់លោក អៀង សារី"។ ទូរសារពីព្រះវររាជបិតា នរោត្តម សីហនុ ព្រះមហាក្សត្រ

៥. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ព្រះមហាក្សត្របានអនុវត្តអំណាចផ្លូវច្បាប់របស់ខ្លួន ស្របតាមច្បាប់រដ្ឋធម្មនុញ្ញ[៩] និងបានត្រាស់បង្គាប់លើកលែងទោសឱ្យ លោក អៀង សារី ចំពោះការផ្តន្ទាទោសឆ្នាំ ១៩៧៩ និងការលើកលែងទោសចំពោះការផ្តន្ទាទោស ក្រោមច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ("ច្បាប់ឆ្នាំ ១៩៩៤")[១០]។ RPA ចែងថា៖

> **មាត្រា ១៖** ត្រូវបានលើកលែងទោសឱ្យ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្តន្ទាទោសប្រហារជីវិតបង់ និងរឹបអូសទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និងចំពោះទោស ដែលបានកំណត់ដោយច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែល ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០១ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤។
>
> **មាត្រា ២៖** ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។
>
> **មាត្រា ៣៖** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជ-ក្រឹត្យនេះ ឱ្យបានសម្រេចជាស្ថាពរ។

៦. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាដំណោះស្រាយ ដែលក្នុងនោះ អង្គបុរេជំនុំជម្រះបានច្រានចោល

---

នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូនលោក Pierre Sané អគ្គលេខាធិការអង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦។

[៨] សេចក្តីបំភ្លឺ ពីព្រះវររាជបិតា នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៦។ សូមមើលផងដែរ ព្រះវររាជបិតា នរោត្តម សីហនុ លើកលែង ទោស លោក អៀង សារី, កាសែតបាងកកប៉ុស្តិ៍ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៦៖ លោកនាយករដ្ឋមន្ត្រីទីពីរ ហ៊ុន សែន បានប្រាប់ព័ត៌មាន Reuters ថា "ព្រះមហាក្សត្របានឡាយព្រះហស្ត លេខា លើកលែងទោស...ដោយមានការគាំទ្រពីសមាជិករដ្ឋសភាចំនួនពីរភាគបី"... លោក ហ៊ុន សែន បាននិយាយថាវាជាការ ងាយស្រួលទេក្នុងការប្រមូលហត្ថលេខាពីសមាជិករដ្ឋសភា នៅក្នុងចំណោមសមាជិករដ្ឋសភាចំនួន ១២០ រូប..."។

[៩] មាត្រា ២៧ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា៖ "ព្រះមហាក្សត្រមានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស"។

[១០] ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦។

អំណះអំណាងរបស់មេធាវីការពារក្ដីដែលថា RPA រារាំងការផ្ដន្ទាទោសនាពេលនេះ[១១]។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេច ដែលបញ្ជាក់ហេតុផលពេញលេញ ដែលក្នុងនោះ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "ដោយពិចារណាថា ការលើកលែងទោសនេះមិនមានអានុភាពលើយុត្តាធិការរបស់ អ.វ.ត.ក ដើម្បីជំនុំជម្រះក្ដីលើ អៀង សារី ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះទេ"[១២]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះបានរកឃើញថា "ការលើកលែងទោស ក្នុងករណី អៀង សារី អាចរារាំងមិនឲ្យមានការជំនុំជម្រះគាត់តែទៅលើបទល្មើសប្រឆាំងសន្តិសុខរដ្ឋ ដូចមានចែងក្នុងមាត្រា ៤ ហើយប្រហែលជាអាចរារាំងទៅលើបទល្មើសនៃសមាជិកភាពក្នុងក្រុមកម្ពុជាប្រជាធិបតេយ្យ ដោយសន្មតថា បទល្មើសទាំងនោះអាចផ្ដន្ទាទោសបានតាមរយៈមាត្រា ១ និងមាត្រា ២"[១៣]។ អង្គបុរេជំនុំជម្រះបានរកឃើញថា RPA មិនអាចទទួលយកបាន ដើម្បីការពារ លោក អៀង សារី ពីការផ្ដន្ទាទោសនៅ អ.វ.ត.ក បានទេ[១៤]។

---

[១១] រឿងក្ដីរបស់ អៀង សារី សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/1/26, ERN: 00634887-00634891 ទំព័រ ៤។

[១២] រឿងក្ដីរបស់ អៀង សារី សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30, ERN: 00661785-00661785 ទំព័រ ១៩៤។

[១៣] ដូចខាងលើ កថាខណ្ឌ ២០០។ មាត្រា ១, ២ និង ៤ នៃច្បាប់ ឆ្នាំ ១៩៩៤ ចែងថាៈ

មាត្រា ១៖ ដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" និងកម្លាំងយោធារបស់ខ្លួនឲ្យនៅក្រៅច្បាប់។

មាត្រា ២៖ ចាប់ពីថ្ងៃដែលច្បាប់នេះ ចូលជាធរមាន ជនទាំងឡាយណាដែលជាសមាជិក អង្គការនយោបាយ និងជាកម្លាំងយោធារបស់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ត្រូវចាត់ទុកជាជនល្មើសនឹងរដ្ឋធម្មនុញ្ញ និងជាជនល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤៖ សមាជិក អង្គការនយោបាយ និងកម្លាំងយោធារបស់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឬជនណាដែលបានប្រព្រឹត្តអំពើៈ

-ធ្វើសកម្មភាពអបគមន៍

-បំផ្លាញរាជរដ្ឋាភិបាល

-បំផ្លាញអង្គការនៃអំណាចសាធារណៈ

៧. នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹង ដល់មេធាវីការពារក្តីថា អង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់ការដេញដោលបញ្ហា RPA ក្នុងនាមជាបញ្ហាអញ្ញត្រកម្ម នៅពេលសវនាការបឋម[១៥]។

II. **ច្បាប់ជាធរមាន**

**ក. អំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការកោះអញ្ជើញសាក្សី**

៨. វិធាន ៨៧(៤) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ "ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត"។

៩. វិធាន ៩៣(១) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា"។

**ខ. ការអនុលោមតាមច្បាប់**

១០. មាត្រា ២៥ នៃកិច្ចព្រមព្រៀង ចែងថា៖

> រាជរដ្ឋាភិបាលកម្ពុជា នឹងអនុវត្តដោយគ្មានការពន្យារពេលតាមការស្នើសុំជំនួយរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះវិសាមញ្ញ ឬក៏បញ្ជារបស់ពួកគេ រួមមាន

---

-ញុះញង់ ឬបង្ខំពលរដ្ឋឲ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ ត្រូវចាត់ទុកជាជនខុសក្រិដ្ឋ ប្រឆាំងនឹងសន្តិសុខក្នុងប្រទេស ហើយត្រូវផ្តន្ទាទោសដាក់ គុកពី ២០ឆ្នាំ ទៅ ៣០ឆ្នាំ ឬអស់មួយជីវិត។

[១៤] រឿងក្តីរបស់ អៀង សារី សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30, ERN: 00661785-00661785 ទំព័រ ១៧៧ ដល់ ២០២។

[១៥] រឿងក្តី នួន ជា សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-អជសជ អនុស្សារណៈផ្ញើពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនគ្រប់ភាគីទាំងអស់ សំណុំរឿង ០០២ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E57/1, ERN: 00658620-00658622 ទំព័រ ២។

00686944



ប៉ុន្តែមិនមែនត្រឹមតែ៖ ក-រកអត្តសញ្ញាណ និងទីកន្លែងរបស់បុគ្គលណាមួយ ខ-ផ្តល់ ឯកសារ គ-ចាប់ខ្លួន ឬឃុំខ្លួនបុគ្គលណាមួយ ឃ-បញ្ជូនជនជាប់ចោទមកកាន់អង្គជំនុំជម្រះវិសាមញ្ញ។

**ខ. អំណាចអនុវត្ត**

១១. វិធាន ៩៣(៣) ចែងថា៖ "ដើម្បីអនុវត្តការស៊ើបសួរបន្ថែម [វិធាន ៩៣(១)] ចៅក្រមអាចចេញដីកាចាត់ឲ្យសួរជំនួសទៅមន្ត្រីនគរបាលយុត្តិធម៌បានដែរ"។

១២. មាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") ចែងថា៖ "សាក្សីត្រូវតែចូលមកបង្ហាញខ្លួននៅមុខតុលាការតាមការកោះហៅ។ តុលាការអាចប្រើកងកម្លាំងសាធារណៈដើម្បីបង្ខំសាក្សីឲ្យចូលបង្ហាញខ្លួន"។

**គ. ភស្តុតាង**

១៣. វិធាន ៨៧(១) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ "លើកលែងមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។

១៤. មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន"[១៦]។

**ឃ. ការបកស្រាយច្បាប់**

១៥. មាត្រា ៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២00៩ ចែងថា៖ "នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ"។

III. **ឧទ្ធរណ៍**

**ក. អង្គជំនុំជម្រះសាលាដំបូងគ្រូវកំណត់អំពីវិសាលភាពនៃ RPA**

[១៦] សេចក្តីបញ្ជាក់បន្ថែម។

១៦. កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រគល់អំណាចឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់វិសាលភាពនៃ RPA[១៧]។ អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចមានដែនកំណត់ ដែលក្នុងនោះអង្គបុរេជំនុំជម្រះអាចធ្វើការកំណត់សម្រេចតែលើអ្វីដែលបានដាក់ជូនប៉ុណ្ណោះ និងមិនអាចស៊ើបសួរលើបញ្ហាអង្គហេតុដោយខ្លួនឯងបានទេ[១៨]។ អង្គបុរេជំនុំជម្រះមិនបានប្រឹងប្រែង ដោយហេតុថាវាមិនអាចធ្វើបាន ដើម្បីស្វែងរកភស្តុតាងពីបុគ្គលអ្នកទទួលខុសត្រូវក្នុងការតាក់តែង ព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោស។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះ បានសំអាងទៅលើសំអាងហេតុ និងន័យតក្កវិជ្ជាដែលមានមន្ទិលសង្ស័យ នៅក្នុងការប្រកាសថាអ្វី ដែលខ្លួនជឿជាក់ថាជាចេតនារបស់អ្នកតាក់តែងព្រះរាជក្រឹត្យនេះទៅវិញ។ ខុសពីអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង មិនត្រូវដាក់កម្រិតខ្លួនទៅក្នុងវិធីនេះឡើយ ព្រោះអង្គជំនុំជម្រះសាលាដំបូង មានសមត្ថភាព និងមធ្យោបាយដើម្បីកោះហៅសាក្សីដែលបានស្នើសុំ ស្វែងរកភស្តុតាង និងកំណត់ពីចេតនារបស់អ្នកតាក់តែងលើកលែងទោស និង អនុគ្រោះទោស ដោយមានភាពប្រាកដប្រជា ច្បាស់លាស់ និងមានតម្លាភាពជាង។

---

[១៧] មាត្រា ១១(២) នៃកិច្ចព្រមព្រៀង ចែងថា: "ប្រការនេះផ្អែកលើសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជាថា រហូតមកដល់ពេលនេះមានតែករណីមួយគត់ ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះ នៅថ្ងៃទី១៤ កញ្ញា ១៩៩៦ ពេលដែលការលើកលែងទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ដែលត្រូវបានផ្តន្ទាទោសនៅឆ្នាំ១៩៧៩ ពីបទប្រល័យពូជសាសន៍។ <u>អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ</u>"។ (សេចក្តីបញ្ជាក់បន្ថែម) មាត្រា ៤០ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ "<u>វិសាលភាពនៃការលើកលែងទោស ឬអនុគ្រោះទោសដែលអាចត្រូវបានផ្តល់ឲ្យមុនការអនុម័តច្បាប់នេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះ វិសាមញ្ញ</u>"។ (សេចក្តីបញ្ជាក់បន្ថែម)។

[១៨] "ការកំណត់សម្រេចផ្នែកអង្គហេតុ [] មិនស្ថិតនៅក្នុងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះនោះ ទេ"។ រឿងក្តីរបស់ អៀង សារី សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30, ERN: 00661785-00661785 កថាខណ្ឌ ២១០។

១៧. នៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបានយល់ឃើញថា សុពលភាពនៃការលើកលែងទោស "មិនមានភាពប្រាកដជាក់លាក់"[១៩] និង៖

នៅក្នុងបរិបទនៃភាពផ្ទុយគ្នាចំពោះការប្រើប្រាស់ពាក្យ "លើកលែងទោស" អង្គបុរេជំនុំជម្រះយល់ឃើញថា "ចំពោះទោស" ដែលមាននៅក្នុងប្រយោគបន្ទាប់ នៃព្រះរាជក្រឹត្យ **<u>អាចត្រូវបានបកស្រាយថា</u>** ជនត្រូវចោទ "នឹងមិនអាចត្រូវតុលាការផ្តួចផ្តើមនីតិវិធីចោទប្រកាន់ចំពោះខ្លួនឡើយ" ដោយសារវាពាក់ព័ន្ធនឹងបញ្ហានៃការដាក់ទោស និងការរំលោភបំពានលើព្រះរាជក្រមលេខ ១/ នស/៩៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៩៩៤។ **<u>អង្គបុរេជំនុំជម្រះនឹងលើកបញ្ហានេះឡើងក្នុងន័យនេះ ដោយសារមានតែការពន្យល់ក្នុងន័យនេះទេ ដែល</u>**ផ្តល់ផលប្រយោជន៍ល្អបំផុតចំពោះជនត្រូវចោទ។

**<u>នៅពេលអនុវត្តការបកស្រាយបែបនេះ</u>** អង្គបុរេជំនុំជម្រះនឹងពិចារណាអំពីអានុភាព ដែលអាចកើតមាន ត្រង់ផ្នែកនេះនៃព្រះរាជក្រឹត្យ[២០]។

១៨. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេ-ជំនុំជម្រះ បានប្រើប្រាស់ "ន័យតក្កវិជ្ជា" ដើម្បីបកស្រាយប្រសិទ្ធិភាពនៃការលើកលែងទោសនៅក្នុងព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោស[២១] ។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ផ្នែកលើកលែងទោសនៃ RPA "**អាចត្រូវបានបកស្រាយថា** មានន័យថា ជនជាប់ចោទ "នឹងមិនត្រូវ

---

[១៩] រឿងក្តីរបស់ អៀង សារី សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ០៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ C22/I/73, ERN: 00232830-00232861 កថាខណ្ឌ ៥៨។

[២០] ដូចខាងលើ កថាខណ្ឌ ៥៩ ដល់ ៦០។

[២១] *រឿងក្តីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30, ERN: 00661785-00661785 កថាខណ្ឌ ១៩២។

ចោទប្រកាន់" ពាក់ព័ន្ធនឹងការកាត់ទោសដែលសម្រេចហើយនោះ ឬការរំលោភបំពានលើ [ច្បាប់ ឆ្នាំ ១៩៩៤] ឡើយ"[២២]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះបានយល់ឃើញថា "**មិនមានចំណុចណាមួយដែលបង្ហាញ**... ថា [ផ្នែកលើកលែងទោសនៃ RPA] **មានគោលបំណង**គ្របដណ្ដប់ទៅលើបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនោះទេ"[២៣]។ ជាចុងក្រោយ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "**ដោយសារតែមិនមានចំណុចណាមួយដែលបង្ហាញថា ព្រះមហាក្សត្រ (និងបុគ្គលនានាដែលបានពាក់ព័ន្ធ) មានព្រះរាជបំណង/បំណង** មិនគោរពតាមកាតព្វកិច្ចជាអន្តរជាតិ របស់ប្រទេសកម្ពុជាក្នុងពេលចេញព្រះរាជក្រឹត្យនោះ **ទើបធ្វើឱ្យការបកស្រាយរបស់សហមេធាវីការពារក្តី ចំពោះឯកសារមួយនេះ** ជាការបកស្រាយដោយគ្មានមូលដ្ឋាន"[២៤]។

១៩. មកដល់ពេលនេះ អង្គបុរេជំនុំជម្រះមានលទ្ធភាពត្រឹមតែធ្វើការបកស្រាយថា **អង្គបុរេជំនុំជម្រះជឿថា** វិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA គឺជាអ្វី តែប៉ុណ្ណោះ។ មាត្រា ៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ ចែងថា៖ "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ"។ ដោយហេតុថាប្រទេសកម្ពុជាបានផ្អែកលើប្រព័ន្ធច្បាប់របស់ប្រទេសបារាំង វិធីនៃការបកស្រាយដែលកំណត់ដោយច្បាប់អាចត្រូវបានសង្ខេបដូចខាងក្រោម៖

១. នៅពេលដែលអត្ថបទច្បាប់មានភាពច្បាស់លាស់ អត្ថបទនោះត្រូវតែអនុវត្តតាម និង មិនត្រូវធ្វើការបកស្រាយទៀតទេ លើកលែងតែលទ្ធផលដែលមិនសមទំនងអាចនឹងកើតមានឡើងនៅពេលបន្ទាប់។

២. នៅពេលដែលអត្ថបទច្បាប់មានន័យមិនច្បាស់លាស់ ឬពិបាកយល់ តុលាការត្រូវស្វែងយល់ពីគោលបំណងនៃការតាក់តែងច្បាប់។ ចំពោះបញ្ហានោះ ជាដំបូង ចៅក្រមត្រូវពិនិត្យមើលអត្ថបទ

---

[២២] ដូចខាងលើ កថាខណ្ឌ ១៩៥ (សេចក្តីបញ្ជាក់បន្ថែម)។

[២៣] ដូចខាងលើ កថាខណ្ឌ ២០០ (សេចក្តីបញ្ជាក់បន្ថែម)។

[២៤] ដូចខាងលើ កថាខណ្ឌ ២០១ (សេចក្តីបញ្ជាក់បន្ថែម)។

នោះដោយប្រុងប្រយ័ត្នជាមុនសិន និងពិនិត្យមើលបទអត្ថាធិប្បាយនានា ដែលសរសេរពាក់ព័ន្ធនឹងច្បាប់នោះ។ ចំណុចនេះមិនកំណត់ត្រឹមបទប្បញ្ញត្តិដែលត្រូវអនុវត្តនោះទេ តែថែមទាំងរួមបញ្ចូលនូវជំពូក ឬច្បាប់ទាំងមូលផងដែរ។ ជាញឹកញាប់ បទប្បញ្ញត្តិមានការពិបាកយល់តែនៅពេលដែលបទប្បញ្ញត្តិនោះត្រូវបានផ្តាច់ចេញពីបរិបទរបស់វា។

៣. ប្រសិនបើការសិក្សាស្វែងយល់បែបនេះនៅតែមិនគ្រប់គ្រាន់ទៀត ជាញឹកញាប់ តុលាការងាកទៅពិនិត្យមើលឯកសារត្រៀមរៀបចំតាក់តែងច្បាប់ ដើម្បីស្រាវជ្រាវរកគំនិតនៃការតាក់តែងអត្ថបទច្បាប់នោះ។ តុលាការកំពូលយល់ព្រមតាមនីតិវិធីនេះ ប៉ុន្តែថែមទាំងលើកឡើងថា ឯកសារត្រៀមរៀបចំតាក់តែងច្បាប់មិនចងកាតព្វកិច្ចតុលាការនោះទេ។ លោក René David ដែលជាអ្នកហៅនីតិវិធីនេះថា ជាវិធីជាប្រវត្តិសាស្ត្រនៃការបកស្រាយច្បាប់ បានដកស្រង់ការប្រើប្រាស់វិធីនេះជាញឹកញាប់ដោយតុលាការនានា។

៤. នៅពេលដែលអត្ថបទច្បាប់មិនផ្តល់នូវដំណោះស្រាយវិវាទដោយផ្ទាល់ទេនោះ យ៉ាងហោចណាស់ ចៅក្រមក៏ត្រូវតែចាប់ផ្តើមពីអត្ថបទច្បាប់ដើម្បីជាមូលដ្ឋាននៃការសម្រេចសេចក្តី។ សេចក្តីសម្រេចរបស់តុលាការបារាំង ជានិច្ចកាលស្ទើរតែផ្អែកលើអត្ថបទច្បាប់ទាំងអស់។ វាជាករណីពិសេសណាស់ សម្រាប់តុលាការដែលមិនយោងលើអត្ថបទច្បាប់នោះ។ ទោះបីជាយ៉ាងណាក៏ដោយ ពេលខ្លះ តុលាការក៏អាចយកគោលការណ៍ច្បាប់ទូទៅមកប្រើប្រាស់ដែរ។

៥. ប្រសិនបើប្រវត្តិតាក់តែងច្បាប់មានភាពច្របូកច្របល់ ឬច្បាប់ចាស់ពេក ចៅក្រមនឹងមើលទៅលើការពិចារណានានាផ្សេងទៀត និងប្រើប្រាស់អ្វីដែលអ្នកស្រាវជ្រាវហៅថា វិធីសាស្ត្របកស្រាយផ្អែកលើគោលបំណងចុងក្រោយនៃការតាក់តែងច្បាប់។ វិធីសាស្ត្រនេះ ភាគច្រើនត្រូវបានប្រើប្រាស់ដោយតុលាការកំពូល តុលាការ Cour de cassation និងតុលាការ Conseil d'État ជាជាងតុលាការសាលាដំបូង[២៥]។

---

[២៥] Claire M. Germain មធ្យោបាយឈានទៅរកការបកស្រាយបញ្ញត្តិច្បាប់ និងប្រវត្តិតាក់តែង ច្បាប់នៅក្នុងប្រទេសបារាំង 13 DUKE J. COMP. & INT'L L. 195, 201–02 (ឆ្នាំ ២00៣)។

២០. ខ្លឹមសារ RPA មានន័យមិនច្បាស់លាស់គ្រប់គ្រាន់ ដែលចាំបាច់ដើម្បីយកភស្តុតាងពីអ្នកទាំងឡាយណា ដែលពាក់ព័ន្ធនៅក្នុងការចរចា ការធ្វើសេចក្តីព្រាង ការយល់ព្រម និងការអនុម័តខ្លឹមសារ RPA [២៦]។ ការវិភាគដ៏តឹងរឹងអាចធ្វើបានត្រឹមតែតាមរយៈសក្ខីកម្មពីសំណាក់អ្នកទាំងឡាយ ដែលបានចូលរួមចរចារធ្វើព្រះរាជក្រិត្យនេះ ពីសំណាក់អ្នកដែលបានយល់ព្រមលើព្រះរាជក្រិត្យនេះ និងពីសំណាក់អ្នកទាំងឡាយដែលបានយល់ដឹងពីអ្វីដែលបានព្រមព្រៀងគ្នាប៉ុណ្ណោះ។ ចំណុចនេះត្រូវបានបញ្ជាក់ដោយអង្គហេតុដែលថា កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រគល់អំណាចឱ្យ អ.វ.ត.ក ជាអ្នកសម្រេចអំពីវិសាលភាពនៃ RPA[២៧]។ ការបកស្រាយដោយចេតនារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងអ្វីដែល *អង្គបុរេជំនុំជម្រះជឿ ឬសន្មត* ថាជាជាវិសាលភាព និងគោលបំណងនៅពីក្រោយ RPA គឺជាការបង្ហាញថែមទៀតថា អត្ថបទនៃ RPA ត្រូវតែបកស្រាយបំភ្លឺឱ្យបានច្បាស់លាស់។

២១. ទាក់ទងនឹងការលើកលែងទោស (pardon) អង្គបុរេជំនុំជម្រះ បានថ្លែងថា "តាមន័យវេយ្យាករណ៍ និងន័យសាមញ្ញដែលប្រើនៅក្នុងព្រះរាជក្រឹត្យ"[28] និងដោយមិនបានឃើញពី"ភាពមិនស្របគ្នា ឬលទ្ធផលមិនប្រក្រតីណាមួយ"[29]។ អង្គបុរេជំនុំជម្រះ បានយល់ឃើញថា "ការលើកលែងទោសឱ្យ អៀង សារី ត្រូវបានកម្រិតត្រឹមការកាត់ទោសជាក់លាក់ដែលត្រូវបានប្រកាសកាលពីឆ្នាំ ១៩៧៩"[30]។ អង្គបុរេជំនុំជម្រះ បានយល់ឃើញបន្ថែមទៀតថា "ការពិតបានបង្ហាញយ៉ាងច្បាស់ថា ទោសប្រហារ

---

[២៦] សារណាបន្ថែមនានាទៅលើចំណុចនេះនឹងដាក់ជូននាពេលខាងមុខ នៅក្នុងសារណាបន្ថែមនានារបស់មេធាវីការពារក្តី ដែលបានបង្គាប់ដោយ អង្គជំនុំជម្រះសាលាដំបូង។ *រឿងក្តី នួន ជា សំណុំរឿង* ០០២/១៩-០៩-២០០៧-អវតក/អជសង អនុស្សារណៈមកពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងមកកាន់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ៥ មេសា ២០១១ ឯកសារលេខ E57/1, ERN: 00658620-00658622 ទំព័រ២។

[២៧] កិច្ចព្រមព្រៀង មាត្រា ១១(២) ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤០។

[28] *រឿងក្តី អៀង សារី សំណុំរឿង* ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ មេសា ២០១១ ឯកសារលេខ D427/1/30, ERN: 00661785-00661785 កថាខណ្ឌ ១៩៣។

[29] ដូចជើងទំព័រខាងលើ ។

[30] ដូចជើងទំព័រខាងលើ ។

ជីវិតប្រាកដជាត្រូវបានប្រែមកជាទោសជាប់ពន្ធនាគារវិញហើយ..."[31]។ ការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងវិសាលភាពនៃការលើកលែងទោស (pardon) តាមរយៈការប្រើប្រាស់ការបកស្រាយបែបតក្កវិជ្ជា និងតាមរយៈការប្រើប្រាស់តាមន័យវេយ្យាករណ៍ និងន័យសាមញ្ញ នឹងនាំអោយមានការបកស្រាយមិនប្រក្រតី ។ បើសិនជា ការបកស្រាយរបស់ អង្គបុរេជំនុំជម្រះ ត្រូវបានគេយកលំនាំតាម ការលើកលែងទោសដែលបានផ្តល់អោយនោះ គឺជារឿងអត់បានការ ព្រោះថា នៅពេលដែល RPA ត្រូវបានគេគាក់តែង ទោសប្រហារជីវិតនៅកម្ពុជាត្រូវបានគេលុបចោលហើយ[32]។ ម្យ៉ាងវិញទៀត វាជាការមិនប្រក្រតីដែលសន្និដ្ឋានថា នៅក្នុងអំឡុងពេលចរចារនានាដែលនាំអោយមានព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោស លោក អៀង សារី ប្រហែលជាបានចរចារអោយទោសប្រហារជីវិតបន្ថយមកត្រឹមទោសអស់មួយជីវិតនោះ។ ការបកស្រាយសមហេតុផលមួយគួរតែថា លោក អៀង សារី បានចរចារអោយមានការលើកលែងទោស ដែលនឹងការពាររូបគាត់ប្រឆាំងនឹងលទ្ធភាពនៃការដាក់ទណ្ឌកម្មណាមួយ។ ដោយហេតុថា ការប្រើន័យវេយ្យាករណ៍ និងន័យសាមញ្ញនឹងនាំអោយមានលទ្ធផលមិនប្រក្រតីមួយ ចេតនាដែលបានចរចារ និងគាក់តែង RPA ត្រូវតែគេបានដឹង។ សក្ខីកម្មរបស់សាក្សីទាំងឡាយ ដែលបានស្នើសុំគឺមានភាពចាំបាច់ដើម្បីកំណត់អំពីវិសាលភាព និង ចេតនានៅពីក្រោយ ព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោស។

២២. វិសាលភាព និងគោលបំណងនៅពីក្រោយ RPA មានសារៈសំខាន់យ៉ាងខ្លាំងណាស់ ទើបលោក David Boyle ដែលជាអតីតមន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្តល់មតិយោបល់ជាសាធារណៈ តាំងពីមុនពេលបង្កើត អ.វ.ត.ក ថា៖

> រឿងក្តីរបស់លោក អៀង សារី គឺជាឧទាហរណ៍ស្តីពីបញ្ហាដែលនឹងកើតឡើងនៅចំពោះមុខ តុលាការកម្ពុជា។ លោក អៀង សារី ត្រូវបានផ្តល់នូវការលើកលែងទោសដែលមានសុពលភាពតាមច្បាប់រដ្ឋធម្មនុញ្ញ និងអភ័យឯកសិទ្ធិចំពោះបទល្មើសមួយចំនួន និងសម្រាប់ការផ្តន្ទាទោសក្រោមច្បាប់ ឆ្នាំ

[31] ដូចដើងទំព័រខាងលើ កថាខណ្ឌ ១៩២។

[32] កម្ពុជាបានលុបបំបាត់ចោលនូវទោសប្រហារជីវិតក្នុងឆ្នាំ ១៩៩៣ ។ មាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ ថ្លែងនៅក្នុងផ្នែកពាក់ព័ន្ធថា "ទោសប្រហារជីវិតត្រូវបានលុបចោល"។

១៩៩៤។ តើការអត់ឱនទោស និងលើកលែងទោសដែលមានសុពលភាពតាមច្បាប់រដ្ឋធម្មនុញ្ញនេះ អាចអនុវត្តនៅចំពោះមុខការជំនុំជម្រះក្តីខ្មែរក្រហមក្នុងវិសាលភាពណាមួយ? បញ្ហានេះត្រូវបានបន្សល់ទុកឱ្យតុលាការធ្វើការសម្រេច[៣៣]។

២៣. ដោយលោក Boyle មានការភ័យខ្លាចខ្លាំងពីវិសាលភាព និងគោលបំណងនៅពីក្រោយ RPA លោកបានផ្តល់មតិយោបល់ថា "បញ្ហា" RPA ៖

> គួរតែត្រូវបានដោះស្រាយជាមុន ដើម្បីចៀសវាងបញ្ហាថា មេធាវីដែលមានភាពប៉ិនប្រសប់នឹងពន្យារពេលការជំនុំជម្រះក្តីបានយ៉ាងងាយស្រួល និងអាចធ្វើឱ្យរយៈពេលបីឆ្នាំជារយៈពេលមិនគ្រប់គ្រាន់ដើម្បីបញ្ចប់នោះទេ។ មានវិធីពីរយ៉ាងដែលអាចធ្វើបានដើម្បីដោះស្រាយបញ្ហាទាំងអស់នេះត្រង់ផ្នែកខ្លះ។ វិធីមួយ គឺចៅក្រមធ្វើការរួមគ្នាជាមួយព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតភ្លាមៗ បន្ទាប់ពីពួកគាត់ត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងដោះស្រាយយ៉ាងច្បាស់លាស់ ពីអ្វីដែលជានីតិវិធីអាចអនុវត្តបានសម្រាប់តុលាការនានា។ ពួកគាត់មិនអាចផ្លាស់ប្តូរច្បាប់បានទេ ប៉ុន្តែពួកគាត់អាចបកស្រាយនូវអ្វីដែលច្បាប់ចង់បាន[៣៤]។

២៤. ដោយមិនគិតគូរពីការកត់សម្គាល់ដ៏គួរឱ្យអាម៉ាស់ដែលថា មេធាវីការពារក្តីនឹងគ្មានអ្វីរួមចំណែក និងគ្រាន់តែមានគោលបំណងបង្អាក់កិច្ចដំណើរការនីតិវិធី និងថា មេធាវីការពារក្តីមិនត្រូវពាក់ព័ន្ធនៅក្នុងការសម្រេចអំពីអត្ថន័យនៃ RPA នោះ លោក Boyle ពិតជាលើកឡើងនូវចំណុចដែលមានសុពលភាពដែលក្នុងនោះវិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA ត្រូវតែធ្វើការ "បកស្រាយ"[៣៥]។

---

[៣៣] របាយការណ៍បានមកពីសន្និសីទដែលធ្វើឡើងនៅទីក្រុងភ្នំពេញ ពីថ្ងៃទី ២ ដល់ទី ៣ ខែ មីនា ឆ្នាំ ២០០៥ ដែលបានរៀបចំដោយ FIDH, LICADHO និង ADHOC *កម្មវិធីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ៖ ការគពប្រសព្វគ្នារវាង តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការខ្មែរក្រហម៖ ទីកន្លែងរបស់ជនរងគ្រោះនានា* ខ. ក្របខ័ណ្ឌច្បាប់របស់ តុលាការខ្មែរក្រហម ទំព័រ ១៨ (សេចក្តីបញ្ជាក់បន្ថែម) អាចបើកមើលបាននៅ៖ http://www.vrwg.org/Publications/02/FIDHcambodge420ang.pdf.

[៣៤] ដូចខាងលើ។

[៣៥] លោក អៀង សារី បានដាក់សំណើសុំព័ត៌មានពាក់ព័ន្ធនឹងភាពសមស្របផ្នែកសីលធម៌ និងវិជ្ជាជីវៈរបស់មន្ត្រីច្បាប់ លោក David Boyle ក្នុងការកាន់តួនាទីបច្ចុប្បន្នរបស់ខ្លួននៅក្នុង ក.ស.ច.ស ដោយលើកឡើងថា ក.ស.ច.ស ក្នុងនាម ជាការិយាល័យឯករាជ្យមួយដែលស្ថិតនៅក្នុង អ.វ.ត.ក ត្រូវបំពេញមុខងារស៊ើបអង្កេតរបស់ខ្លួនប្រកបដោយភាព អនាគតិ។ ក្នុងនោះ ព័ត៌មានដែលត្រូវបាន

00686952



ស្នើសុំ រួមមានបញ្ជីរឿងគ្រប់យ៉ាងដែលនិពន្ធដោយលោក Boyle, សន្និសីទ, វគ្គបណ្ដុះបណ្ដាល, សវនាការដេញដោល, ការបង្រៀន, សិក្ខាសាលា និងកិច្ចប្រជុំនានាដែលលោក Boyle បានចូលរួម ពាក់ព័ន្ធទៅនឹង អ.វ.ត.ក ឬ សាលាក្ដីខ្មែរក្រហម ការពណ៌នាអំពីការចូលរួមរបស់លោក Boyle នៅក្នុងការធ្វើសេចក្ដីព្រាងដីកា សម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងការពន្យល់អំពីអ្វីដែល ក.ស.ច.ស បានដឹង ទាក់ទិននឹងតួនាទី និងការនិពន្ធរបស់លោក Boyle នៅពេលជាប់កិច្ចសន្យាការងារ។ *រឿងក្ដីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានពាក់ព័ន្ធនឹងភាពលម្អៀងដែលអាចមើលឃើញ និងទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើង របស់មន្ត្រីច្បាប់របស់ ក.ស.ច.ស លោក David Boyle A162, ERN: 00165542-00165547។ *សូមមើលផងដែរ រឿងក្ដីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតដែលមានចំណងជើងថា "សំណើពាក់ព័ន្ធនឹងការសាកសួរចម្លើយលោក អៀង សារី អំពីស្ថានភាពនៃការឃុំខ្លួនរបស់គាត់ នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០០៨" ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨ ឯកសារA121/II, ERN: 00185454-00185456 ទំព័រ ២ ដល់ ៣។ ក.ស.ច.ស បានឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្ដីនៅក្នុងលិខិតចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៨ ដោយលើកឡើងថា "មិនមានមូលដ្ឋានគតិយុត្តិណាមួយសម្រាប់ការស្នើសុំដែលៗបែបនេះទេ"។ និងថា "វិធានផ្ទៃក្នុង របស់ អ.វ.ត.ក មិនមានចែងអំពីលទ្ធភាពណាមួយចំពោះភាគីធ្វើបណ្ដឹងជំទាស់ចិត្តអ្នកស៊ើបអង្កេតណាម្នាក់ទេ"។ លិខិត របស់ ក.ស.ច.ស បានបង្ហាញទាំងការយល់ច្រឡំអំពីសំណើសុំ ទាំងការបដិសេធដោយក្ដីបារម្ភក្នុងការផ្ដល់ព័ត៌មានដែលបានស្នើសុំ។ លិខិតនោះក៏បានបង្ហាញផងដែរពីឆន្ទានុសិទ្ធិរបស់ ក.ស.ច.ស ក្នុងការបង្ការការប៉ុនប៉ងនាថ្ងៃអនាគតដោយ មេធាវីការពារក្ដីក្នុងការកែប្រែការយល់ច្រឡំនេះ។ លិខិតក៏បានបដិសេធមុនពេលកំណត់អំពីការប៉ុនប៉ងដែលអាចមាន នាថ្ងៃអនាគតក្នុងការប្ដឹងជំទាស់ចិត្តលោក Boyle។ *រឿងក្ដីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានពាក់ព័ន្ធនឹងភាពលម្អៀងដែលអាចមើលឃើញ និងទំនាស់ផលប្រយោជន៍ពាក់ព័ន្ធនឹង លោក MMS. Heder និង D. Boyle" ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ឯកសារ A121/III, ERN: 00193591-00193591។ មេធាវីការពារក្ដីបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងលិខិតរបស់ ក.ស.ច.ស នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៨។ *រឿងក្ដីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ០៨) បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស *លើសំណើរបស់មេធាវីសុំព័ត៌មានទាក់ទងនឹងភាពលម្អៀងដែលឃើញ ច្បាស់ និង អត្ថិភាពដ៏មានសក្ដានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក ដេវីដ បយល៍ (David Boyle)* ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារ A162/III/1, ERN: 00195028-00195035។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា បណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ ពីព្រោះ អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការក្នុងការស្ដាប់ការសួរដេញដោលអំពីបញ្ហានោះទេ។ *រឿងក្ដីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ០៨) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះលិខិតដែលពាក់ព័ន្ធនឹងសំណើសុំព័ត៌មានអំពីមន្ត្រីច្បាប់លោក ដេវីដ ប៊យល៍ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ A162/III/6, ERN: 00221204-00221208។ សូមមើលផងដែរ *រឿងក្ដីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-អបជ បណ្ដឹងជំទាស់ចិត្តរបស់ អៀង សារី ទៅលើអ្នកស៊ើបអង្កេត ក.ស.ច.ស Stephen Heder និងមន្ត្រីច្បាប់ ក.ស.ច.ស David Boyle ដែលបម្រើការងារនៅការិយាល័យសហចៅក្រម ស៊ើបអង្កេត ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ

២៥. អង្គជំនុំជម្រះសាលាដំបូងត្រូវមើលទៅលើវិសាលភាពដែលបានគ្រោងទុកនៃ RPA ដូចបានឆ្លុះបញ្ចាំងតាមរយៈគោលបំណងរបស់អ្នកទាំងឡាយដែលបានដឹកនាំការចរចាអំពី RPA និងការអនុវត្ត RPA ដូចជា លោក អៀង សារី, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ, សម្តេចព្រះវររាជបិតា នរោត្តម សីហនុ និងសម្តេច ជា ស៊ីម ជាដើម។ សក្ខីកម្មពីសាក្សីដែលត្រូវបានស្នើសុំ នឹងធ្វើឲ្យការបកស្រាយ ការប៉ាន់ស្មាន ឬការពឹងផ្អែកលើពាក្យចចាមអារ៉ាមទាំងនោះ លែងជាការចាំបាច់ទៀតហើយ។

**ខ. តម្លៃភស្តុតាងដែលមានត្រូវយកទៅពិចារណានៅពេលសម្រេចលើវិសាលភាពនៃ RPA**

២៦. មកដល់ពេលនេះ វិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA ត្រូវបានបកស្រាយតែតាមរយៈពាក្យចចាមអារ៉ាម និងប្រភពបន្ទាប់បន្សំផ្សេងទៀតប៉ុណ្ណោះ។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានលើកឡើងយ៉ាងច្បាស់លាស់ថា "តុលាការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ"។ ទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទាំងវិធានផ្ទៃក្នុង មិនបានចែងអំពីគោលការណ៍ណែនាំថែមទៀត ពាក់ព័ន្ធនឹងបញ្ហាថាតើត្រូវឲ្យតម្លៃលើភស្តុតាង តាមវិធីណាឡើយ[៣៦]។ គោលការណ៍ណែនាំត្រូវបានផ្តល់ឲ្យ និងអាចរកបានពីតុលាការ*មិនអចិន្ត្រៃយ៍*នានា[៣៧]។ នៅក្នុងរឿងក្តី *Kordić* និង *Čerkez* អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY កំណត់គោលការណ៍ណែនាំដើម្បីសម្រេច "សញ្ញានៃភាពអាចជឿទុកចិត្តបាន" នៃភស្តុតាងជាពាក្យ

---

២០០៩, ១, ERN: 00348412-00348440។ *រឿងក្តីរបស់ អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-អបជ សាលដីកាលើបណ្តឹងជំទាស់ដិតចិត្តរបស់ជន ត្រូវចោទទៅលើលោកបណ្ឌិត Spephen Heder និងលោកបណ្ឌិត David Boyle ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩, ៣, ERN: 00378097-00378103។

[៣៦] មេធាវីការពារក្តីពិតជាបានកត់សម្គាល់លើវិធាន ៨៧(៥) នៃវិធានផ្ទៃក្នុង ដែលចែងថាៈ "អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការថ្លឹងថ្លែងពិចារណានូវចម្លើយសារភាព ដូចគ្នានឹងប្រភេទនៃភស្តុតាងដទៃទៀតដែរ"។ ទោះបីជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងមិនបានចែងអំពីតម្លៃដែលត្រូវផ្តល់ឲ្យ "ទម្រង់ផ្សេងទៀតនៃភស្តុតាង" នោះទេ។

[៣៧] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ ថ្មី ចែងថា៖ "ប្រសិនបើនីតិវិធីដែលមានស្រាប់ ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្រប នៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

ចចាមអារ៉ាម ដែលបានរួមនូវបញ្ហាថាតើសេចក្តីថ្លែងការណ៍ដែលបានលើកឡើង៖ ក. ត្រូវបានធ្វើឡើងតាមការស្បថ ខ. ត្រូវធ្វើការសាកសួរដេញដោល គ. ត្រូវបានទទួលផ្ទាល់ទាំងស្រុង ឬត្រូវបានកែប្រែ ឃ. ត្រូវបានធ្វើឡើងដំណាលគ្នានឹងព្រឹត្តិការណ៍ ង. ត្រូវបានធ្វើឡើង តាមរយៈការបកប្រែ [និង][ឬ] ច. ត្រូវបានធ្វើឡើង ក្រោមកាលៈទេសៈជាផ្លូវការ ដូចជានៅចំពោះមុខចៅក្រម[៣៨]។ នៅក្នុងរឿងក្តី *Limaj et al.*, អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានលើកឡើងថា "អង្គជំនុំជម្រះត្រូវបានតម្រូវឱ្យធ្វើការថ្លឹងថ្លែង និងវាយតម្លៃលើភស្តុតាងដែលបង្ហាញដោយគ្រប់ភាគីទាំងអស់។ អង្គជំនុំជម្រះផ្ទុះបញ្ជាក់ថា ការទទួលយកតែភស្តុតាងនៅក្នុងដំណើរការជំនុំជម្រះក្តីពុំរារាំងដល់ការថ្លឹងថ្លែងដែលអង្គជំនុំជម្រះត្រូវភ្ជាប់ទៅនឹងភស្តុតាងនោះនៅពេលបន្ទាប់"[៣៩] នោះទេ។ ចៅក្រម Sidhwa អង្គជំនុំជម្រះ សាលាដំបូងរបស់តុលាការ ICTY នៅក្នុងរឿងក្តី *Rajić* បានលើកឡើងថា **"ពុំមានតុលាការ ដែលត្រូវបានចោទប្រកាន់ថា ដឹកនាំការជំនុំជម្រះក្តីដោយយុត្តិធម៌ណាមួយ នឹងទទួលយកភស្តុតាងប្រយោល ឬភស្តុតាងមិនសំខាន់នោះទេ ប្រសិនបើមានភស្តុតាងផ្ទាល់ និងមិនត្រូវបានបង្កើតឡើងដោយគ្មានហេតុផលសមស្របទេនោះ"**[៤០]។

២៧. មានរបាយការណ៍ព័ត៌មានដែលមានទំនាស់គ្នា ពាក់ព័ន្ធនឹងវិសាលភាព និងគោលបំណងនៅពីក្រោយការផ្តល់ RPA ។ ឧទាហរណ៍ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានរាយការណ៍ថា សម្តេចបានមានប្រសាសន៍ថា៖ "ដើម្បីផលប្រយោជន៍ជាតិ យើងត្រូវធ្វើវា [ដូចជា ផ្តល់ RPA ឱ្យលោក អៀង សារី]។ ដើម្បីបំផ្លាញកងកម្លាំងខ្មែរក្រហមចំនួន ៧០% យើងត្រូវចំណាយផងដែរ - នោះគឺការលើកលែងទោសដែលត្រូវផ្តល់ដល់លោក អៀង សារី"[៤១]។ សកម្មភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន

---

[៣៨] រឿងក្តី *Prosecutor v. Kordić and Čerkez*, IT-95-14/2-AR73.5 សាលដីកាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ស្តីពីសាក្សីដែលបានស្លាប់ហើយ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខណ្ឌ ២៧។

[៣៩] រឿងក្តី *Prosecutor v. Limaj et al.*, IT-03-66-T សាលក្រម ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កថាខណ្ឌ ១២។

[៤០] រឿងក្តី *Prosecutor v. Rajić*, IT-95-12-R61 សេចក្តីសម្រេចអនុលោមតាមវិធាន ៦១ - គំនិតដោយឡែករបស់ ចៅក្រម Sidhwa ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ២៥ (សេចក្តីបញ្ជាក់បន្ថែម)។

[៤១] TOM FAWTHROP & HELEN JARVIS, ការគេចចេញពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍: យុត្តិធម៌ដែលពិបាកបរិយាយ និងតុលាការខ្មែរក្រហម ១៣៧ (Pluto Press ឆ្នាំ ២០០៤)។

សែន ដែលត្រូវបានរាយការណ៍ បង្ហាញថែមទៀតថា វិសាលភាពនៃ RPA មានភាពទូលំទូលាយណាស់។ ឧទាហរណ៍ នៅខែ សីហា ឆ្នាំ ១៩៩៨ បន្ទាប់ពីការចាប់ខ្លួនអតីតសមាជិកខ្មែរក្រហម នួន ប៉ែត ចំពោះសកម្មភាពរបស់គាត់ដែលជាផ្នែកមួយរបស់ខ្មែរក្រហម សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានរាយការណ៍ថា បានបញ្ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា ទៀ បាញ់ ទៅធ្វើការធានាអះអាងឡើងវិញជាមួយលោក អៀង សារី ថា អភ័យឯកសិទ្ធិដែលបានផ្តល់ឲ្យគាត់ មិនធ្វើឲ្យគាត់ប្រឈមនឹងការកាត់ទោសនោះទេ[៤២]។

២៨. ផ្ទុយទៅនឹងសកម្មភាពរបស់គាត់ និងសេចក្តីថ្លែងការណ៍កាលពីមុន នៅខែ តុលា ឆ្នាំ ២០០៤ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានរាយការណ៍ថា សម្តេចបានបញ្ជាក់ពីគំនិតថា "ប្រសិនបើអ្នកសិក្សាពាក្យ [RPA] អ្នកនឹងយល់ថា នៅតែមានលទ្ធភាពក្នុងការកាត់ទោសបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តដោយ លោក អៀង សារី ... យើងបានយកចិត្តទុកដាក់ខ្លាំងណាស់ក្នុងការប្រើប្រាស់ពាក្យលើកលែងទោស ... គ្មានពាក្យណាមួយក្នុងពាក្យនោះដែលរារាំងការចោទប្រកាន់លោក អៀង សារី នៅចំពោះមុខតុលាការ ដែលអាចនឹងត្រូវបានបង្កើតឡើងនាពេលខាងមុខនេះទេ"[៤៣]។

២៩. ខ្លឹមសារដែលមានលក្ខណៈផ្ទុយគ្នានៃរបាយការណ៍ព័ត៌មានទាំងអស់នេះ បានបង្ហាញថា របាយការណ៍ព័ត៌មាន មិនអាចធ្វើជាសំអាងដើម្បីកំណត់ព្រំដែនវិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA បានទេ។ កាន់តែសំខាន់ជាងនេះទៀត សេចក្តីថ្លែងការណ៍ និងសកម្មភាពរបស់សម្តេច ហ៊ុន សែន ដែលត្រូវបានរាយការណ៍ទាំងអស់នេះ គឺជាពាក្យចចាមអារ៉ាម។ គ្មានរបាយការណ៍ព័ត៌មាន ឬសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានផ្តល់ឲ្យដោយមានការស្បថ

---

[៤២] John A. Hall *នៅក្នុងស្រមោលនៃតុលាការខ្មែរក្រហម៖ ការជំនុំជម្រះក្តីក្នុងប្រទេសលើ នួន ប៉ែត, ឈូក រិន និង សំ ប៊ិត និងការស្រាវជ្រាវរកធម្មានុរូបភាពតុលាការនៅក្នុងប្រទេសកម្ពុជា* 5 LAW & PRAC. INT'L CTS. & TRIBUNALS 425 (ឆ្នាំ ២០០៦) ("Hall")។

[៤៣] TOM FAWTHROP & HELEN JARVIS ការគេចចេញពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍: យុត្តិធម៌ដែលពិបាកបរិយាយ និងតុលាការខ្មែរក្រហម ១៧២ (សាកលវិទ្យាល័យ New South Wales Press Ltd ឆ្នាំ ២០០៥) ដកស្រង់របស់សម្តេច ហ៊ុន សែន៖ *Cambodia United at any Price* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ពីថ្ងៃទី ៤ ដល់ទី ៦ ខែ តុលា ឆ្នាំ ១៩៩៤។

នោះទេ។ គ្មានរបាយការណ៍ព័ត៌មាន ឬសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវយកធ្វើការសួរចម្លើយនោះទេ។ វាទំនងឲ្យជឿខ្លាំងណាស់ថា សេចក្តីថ្លែងការណ៍ដែលបានគ្រោងទុករបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានធ្វើឡើងជាភាសាខ្មែរ ហើយមិនមានការបកប្រែ និងផ្សព្វផ្សាយជាភាសាអង់គ្លេសនោះទេ។ គ្មានរបាយការណ៍ព័ត៌មាន ឬសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានធ្វើឡើងក្រោមកាលៈទេសៈផ្លូវការ ដូចជា នៅចំពោះមុខចៅក្រមនោះទេ ហើយសេចក្តីថ្លែងការណ៍ទាំងនោះ ពិតជាមិនមែនជាសេចក្តីថ្លែងការណ៍ដែលមេធាវីការពារក្តី ត្រូវតតាំងនៅចំពោះមុខតុលាការនោះទេ[៤៤]។

៣០. សម្តេចព្រះវររាជបិតា នរោត្តម សីហនុ, នាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម សុទ្ធតែនៅមានព្រះជន្ម/មានជីវិត និងអាចផ្តល់ភស្តុតាងបាន។ គ្មានហេតុផលសមស្របណាមួយដែលរារាំងសាក្សីដែលត្រូវបានស្នើសុំមិនឲ្យថ្វាយ និងផ្តល់សក្ខីកម្មនោះទេ។ អ្នកទាំងអស់គ្នានឹងលើកឡើងពីបញ្ហាសម្ងាត់ស្តីពីវិសាលភាពនៃ RPA។ ពុំមានសាក្សីណាមួយ នឹងត្រូវដាក់ឲ្យទទួលខុសត្រូវរឿងព្រហ្មទណ្ឌណាមួយឡើយ។ ពុំមានសាក្សីណាម្នាក់គឺជាជនជាប់សង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទនោះទេ ហេតុនេះ ពុំមានសាក្សីណាម្នាក់មានសិទ្ធិទទួលបានសិទ្ធិក្នុងការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ។ សាក្សីទាំងនេះគឺគ្រាន់តែជាសាក្សីផ្តល់ភស្តុតាងដូចសាក្សីផ្សេងទៀតតែប៉ុណ្ណោះ។

---

[៤៤] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង ចែងថា៖ “សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុង មាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបាន គោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេស រួមមាន ... សិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បបន្ទុក”។ មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖ “នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា សមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ...ដើម្បីពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នា និងភស្តុតាងដាក់បន្ទុកដែរ”។ វិធាន ៨៧(២) នៃវិធានផ្ទៃក្នុង ចែងថា៖ “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល”។ មាត្រា ១៤(៣)(ង) នៃកតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា៖ ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពី បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ... ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក”។

ដើម្បីឱ្យសក្ខីកម្មរបស់ពួកគាត់កាន់តែមានតម្លៃ ការសាកសួរសាក្សី ដែលត្រូវបានស្នើសុំទាំងអស់គឺជាការចាំបាច់។ មានភស្តុតាងផ្ទាល់ពាក់ព័ន្ធនឹងវិសាលភាព និងគោលបំណងនៅពីក្រោយ RPA។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនយាង និងកោះអញ្ជើញសាក្សី ដែលត្រូវបានស្នើសុំឱ្យថ្វាយ និងផ្តល់សក្ខីកម្មទេនោះ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវផ្តល់តម្លៃដល់ភស្តុតាង ជាពាក្យចចាមអារ៉ាមដែលគ្មានការអះអាងបន្ថែមនោះឡើយ។

**គ. អង្គជំនុំជម្រះសាលាដំបូងមានមធ្យោបាយកោះអញ្ជើញ និងអនុវត្តការកោះអញ្ជើញ**

៣១. ស្របតាមវិធាន ៨៧(៤) និង ៩៣(១) អង្គជំនុំជម្រះសាលាដំបូងអាចកោះអញ្ជើញ ឬស្តាប់ការសួរដេញដោលបុគ្គលណាម្នាក់ក្នុងនាមជាសាក្សី អាចទទួលយកភស្តុតាងថ្មី ឬដឹកនាំកិច្ចស៊ើបសួរថ្មីដែលចាំបាច់ដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថានាំឱ្យស្វែងរកឃើញនូវការពិត។ ស្របតាមវិធាន ៩៣(៤) និងមាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អង្គជំនុំជម្រះសាលាដំបូងអាចប្រើប្រាស់នគរបាលយុត្តិធម៌ ប្រសិនបើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម មិនប្រតិបត្តិតាមការយាង និងកោះអញ្ជើញដែលបានចេញផ្ញើជូនពួកគាត់។ លើសពីនេះទៀត អនុលោមតាមមាត្រា ២៥ នៃកិច្ចព្រមព្រៀង រដ្ឋាភិបាលកម្ពុជា - ដែលរួមមានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសម្តេច ជា ស៊ីម - ត្រូវតែជួយ អ.វ.ត.ក ក្នុងករណីមានសំណើសុំជំនួយណាមួយ។ ពុំមានបញ្ញត្តិណាមួយរារាំងអង្គជំនុំជម្រះសាលាដំបូងមិនឱ្យស្នើសុំសម្តេចព្រះវររាជបិតានរោត្តម សីហនុ មិនឱ្យព្រះអង្គថ្វាយសក្ខីកម្មនោះឡើយ។

IV. **សំណូមពរដែលបានស្នើសុំ**

**ហេតុដូច្នេះ** តាមហេតុផលដូចដែលបានរៀបរាប់ក្នុងញត្តិ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំ-ជម្រះសាលាដំបូងមេត្តាយាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម ដើម្បីថ្វាយ និងផ្តល់សក្ខីកម្មនៅក្នុងតុលាការអំពីសារតារ វិសាលភាព និងគោលបំណងដែលនៅពីក្រោយ RPA នៅពេលសវនាការបឋម។

សូមអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលនូវការគោរពដ៏ស្ម័គ្រស្មោះអំពីយើងខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

អាង ឧត្តម     Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០១១